# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**

**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**


លេខ.................. ស.ខ.ក.ក.

## សេចក្តីថ្លែងការណ៍

តាមប្រភពពត៌មានពីវិទ្យុផ្សាយសម្លេងវៀតណាម និងពត៌មានពីគេហទំព័រ(Internet) វៀតណាម Can tho បានផ្សាយថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៧ឱ្យដឹងថា ព្រះតេជគុណទឹម សាខន ព្រះចៅអធិការវត្តភ្នំដិនខាងជើង ស្រុកគិរីវង់ ខេត្តតាកែវ ត្រូវបានអាជ្ញាធរវៀតណាមឃុំឃាំងក្នុងពន្ធនាគារនៃប្រទេសវៀតណាម ដោយចោទប្រកាន់ពីបទឆ្លងដែនខុសច្បាប់ចូលប្រទេសវៀតណាម និងបំផ្លិចបំផ្លាញគោលនយោបាយសាមគ្គីភាពកម្ពុជា-វៀតណាម ។

យោងតាមការចោទប្រកាន់របស់អាជ្ញាធរវៀតណាម ដែលថាព្រះតេជគុណទឹម សាខន ឆ្លងដែនចូលប្រទេសវៀតណាមដោយខុសច្បាប់នោះ អាចបញ្ជាក់បានថា ព្រះតេជគុណទឹម សាខន ជាពលរដ្ឋខ្មែរយ៉ាងពិតប្រាកដ ។ ដូចនេះរាជរដ្ឋាភិបាលខ្មែរមានកាតព្វកិច្ចការពារពលរដ្ឋខ្មែរស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់សញ្ជាតិ ដែលកំពុងស្ថិតនៅជាធរមាន ។ តើនរណាមួយ ឬអង្គភាពណាមួយ ដែលជាអ្នកទទួលខុសត្រូវចំពោះការចាប់បញ្ជូនខ្លួនព្រះតេជគុណទឹម សាខន ទៅឱ្យអាជ្ញាធរវៀតណាម? បើតាមការអះអាងរបស់លោកឧត្តមសេនីយ៍ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានប្រាប់បណ្តាញសារពត៌មានកាលពីពេលថ្មីៗនេះថាអាជ្ញាធររបស់ លោកបានបញ្ជូនព្រះតេជគុណទឹម សាខនទៅប្រទេសវៀតណាម តាមការស្នើសុំរបស់ព្រះអង្គដោយមានលិខិតជាលាយលក្ខណ៍អក្សរត្រឹមត្រូវ ។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា អង្គការជាតិ-អន្តរជាតិ និងបណ្តាស្ថានទូតនានាប្រចាំព្រះរាជាណាចក្រកម្ពុជា មេត្តាតាមឃ្លាំមើល និងការពារសុវត្ថិភាពជូនព្រះតេជគុណទឹម សាខន ដែលកំពុងជាប់ពន្ធនាគារនៅប្រទេសវៀតណាម ។ ជាមួយគ្នានេះ សហគមន៍ខ្មែរកម្ពុជាក្រោម សូមអំពាវនាវយ៉ាងទទូចដល់រាជរដ្ឋាភិបាលខ្មែរ មេត្តាធ្វើអន្តរាគមន៍គ្រប់មធ្យោបាយការទូតដើម្បីនាំយកព្រះតេជគុណទឹម សាខនត្រឡប់មកវិញ និងបើកការស៊ើបអង្កេតយ៉ាងល្អិតល្អន់មួយចំពោះករណី ចាប់បញ្ជូនខ្លួនព្រះតេជគុណទឹម សាខនទៅឱ្យអាជ្ញាធរវៀតណាម រួមទាំងលិខិតស្នើសុំរបស់ព្រះតេជគុណទឹម សាខននោះផង ដើម្បីរកមុខរកជនល្មើសរំលោភរដ្ឋធម្មនុញ្ញយកមកផ្តន្ទាទោសតាមផ្លូវច្បាប់ ។

ភ្នំពេញ, ថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៧

នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

ថាច់ សេដ្ឋា

អតីតសមាជិកព្រឹទ្ធសភា